BMI00145

# សម្ភាសន៍ជាមួយឈ្មោះ វ៉ុន ថន ភេទស្រី អាយុ៥២ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ "ប្រធានក្រុម"

ស្រុកកំណើតនៅភូមិពោធិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិពោធិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤៨:០៤

២៤ទំព័រ

ប៊ុនថន ៖ មីងឈ្មោះអីដែរអ្នកមីង?

ថន ៖ ខ្ញុំឈ្មោះ វ៉ុន ថន ។

ប៊ុនថន ៖ វ៉ុន ថន?

ថន ៖ ចាស!

ប៊ុនថន ៖ មីងអាយុប៉ុន្មានហើយអ្នកមីង?

ថន ៖ ខ្ញុំសព្វថ្ងៃ៥២ ។

ប៊ុនថន ៖ ៥២ឆ្នាំ ។ មីងកើតនៅភូមិឃុំអីដែរអ្នកមីង?

ថន ៖ កើតនៅឃុំនេះឯង ភូមិពោធិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យនេះឯង ។

ប៊ុនថន ៖ បងប្អូនប៉ុន្មាននាក់អ្នកមីង?

ថន ៖ ខ្ញុំតែពីរនាក់បងប្អូន បីនាក់មួយទៀតទៅថៃបាត់ហើយ ។

ប៊ុនថន ៖ បីនាក់ ។ ប្រុសប៉ុន្មាន?

ថន ៖ ប្រុសមួយ ស្រីពីរ ។

ប៊ុនថន ៖ ហើយមីងកូនទីប៉ុន្មាន?

ថន ៖ ខ្ញុំកូនទីពីរ ។

ប៊ុនថន ៖ កូនទីពីរ ។ ឪពុកម្ដាយនៅដែរអត់អ្នកមីង?

ថន ៖ ខូចអស់ហើយ នៅផ្ទះតែខ្ញុំ ។

ប៊ុនថន ៖ ផ្ទះចាស់អ្វី ។ ខូចអស់ជំនាន់ណាដែរ?

ថន ៖ ខូចជំនាន់នេះឯង ។

ប៊ុនថន ៖ ក្រោយទេ?

ថន ៖ ចាស!

ប៊ុនថន ៖ ខូចដោយសារអីដែរមីង?

ថន ៖ គាត់ជំងឺខ្លួនគាត់ ។

ប៊ុនថន ៖ មីងរៀនដល់ណាដែរកាលពីតូច?

ថន ៖ ខ្ញុំរៀនថ្នាក់ទី៩ អាពតចូល ។

ប៊ុនថន ៖ ទី៩?

ថន ៖ ចាស! ទី៩ពីដើមមិញណា ទី៩ពីដើមមិញយើងរាប់ពីថ្នាក់ទី១២មក បានចូលទី៨ មិនបានពាក់កណ្ដាលផងណា អាពតចូល ថ្នាក់ទី៨ ។

ប៊ុនថន ៖ ៩ចាស?

ថន ៖ ចាស!

ប៊ុនថន ៖ រៀននៅសាលាណាដែរមីង?

ថន ៖ រៀនសាលាព្រះនេត្រព្រះនេះឯង ។

ប៊ុនថន ៖ ព្រះនេត្រព្រះ ។ មីងឈប់រៀននៅពេលណាមីង?

ថន ៖ ឈប់នៅពេលពួកខ្មែរក្រហមចូលមក វៀតណាមចូលមក ខ្ញុំក៏ឈប់ទៅ ដល់ពេលវៀតណាមចូលវិញ វាធំជ្រុលទៅហើយ ។

ប៊ុនថន ៖ ឈប់រៀន?

ថន ៖ ចាស!

ប៊ុនថន ៖ ចុះពេលខ្មែរក្រហមចូលមកហ្នឹងមីងនៅភូមិនេះដដែលអ្វីមីង?

ថន ៖ អត់ទេ គេឲ្យទៅនៅស្រែះ ។

ប៊ុនថន ៖ ទៅនៅស្រែះ?

ថន ៖ ចាស! ជម្លៀសនិយាយអាមុនដំបូង ។

ប៊ុនថន ៖ បាទ! ជម្លៀសទៅនៅ ទៅទាំងអស់អីអ្នកមីង?

ថន ៖ ទៅទាំងភូមិ គ្រួសារទាំងអស់ ។

ប៊ុនថន ៖ ខាងណាមកជម្លៀសអ្នកមីង?

ថន ៖ មិនដឹងមកពីខាងណា គេដេញឲ្យទៅស្រែក៏ទៅទៅ ទៅនៅណោះ ស្រែនេះ។ កាលជំនាន់នេះឯង វ៉ៃគណៈឃុំគណៈអីចោល ឃើញតែមុខៗហ្នឹង មានមាសមានអីឲ្យគេអស់។ គេប្រមូលដាក់ថាត្រង់នេះ ត្រង់ណោះ មាសគេមកដាក់យកទៅអស់ នៅតែខ្លួន គ្មានស្អី។

ប៊ុនថន ៖ ហ្នឹងខាងណាប្រមូលមីង?

ថន ៖ ខាងពួកគេដែលបញ្ជូនទៅហ្នឹង។ កាលអាពតហ្នឹងឯងគេអ្នកប្រមូលទៅ មិត្តណាមានអីៗចុះ ត្រូវតែប្រមូលដាក់ឲ្យ បើមិនអីចឹងទេគេវ៉ៃចោល។

ប៊ុនថន ៖ ចុះមានអ្នកលួចទុកអី?

ថន ៖ គ្មានអ្នកណាហ៊ានទុកទេ។ មីងអ្នកជម្លៀសទៅស្រែហ្នឹង មកពីណាខ្លះជម្លៀសទៅហ្នឹងមីង?

ប៊ុនថន ៖ ភូមមួយព្រះនេត្រព្រះទៅស្រែ។ ភាគច្រើនទៅស្រែ ទៅភូមិជាំង គេហៅផ្សារកប្បាស។

ថន ៖ ភូមិជាំងនេះនៅឃុំព្រះនេត្រព្រះនេះដែរមីង?

ជិតខាង ៖ ឃុំជប់បូរី។

ប៊ុនថន ៖ ទេ! ប៊ុនគេបញ្ជូនទៅឲ្យកន្លែង។

ជិតខាង ៖ កាលពីមុនមកគេបញ្ជូនឲ្យយើងទៅនៅណា។

ថន ៖ ធ្វើម៉េចឲ្យយើងចេញពីស្រែមក

ជិតខាង ៖ ដល់យើងចេញពីស្រែមកយើងទៅនៅភូមិប៉ោយគ្លៀង។

ថន ៖ ដល់ទៅនៅស្រែនេះនៅគៀនដើងផ្នុង បាំងជម្រក បរទេះ ទៅនៅហ្នឹង។

ប៊ុនថន ៖ ច្រើនគ្រួសារដែរអ្នកមីង?

ថន ៖ ដល់ពេលទៅនៅនោះដូចមានជម្រកទៅ គេជម្លៀសចេញពីភូមិនេះឲ្យទៅនៅភូមិប៉ោយគ្លៀង។ ដេញមកពីស្រែមកវិញ គេចម្រាញ់យកអាក្រក់ៗដូចប្រធានឃុំ ដូចជាអីគេយកវ៉ៃចោលអស់ទៅ ក៏នៅដូចកូនចៅអីទៅ អ្នកណាមានឪទាហានអីគេចាប់ទៅអស់ អ្នកអត់ បរិសុទ្ធគេឲ្យមកភូមិវិញ ភូមិប៉ោយគ្លៀង។

ប៊ុនថន ៖ នៅហ្នឹងគេចាប់ផ្ដើមចម្រាញ់រកអ្នកណាដែលធ្វើ?

ថន ៖ អ្នកណាដែលមានឪធ្វើទាហាន ប្រវត្តិធ្វើទាហានធ្វើអី។

ប៊ុនថន ៖ គេចាប់នៅស្រែហ្នឹង?

ថន ៖ ស្រេចតែប្រធានកង គេចាប់វៃនៅមុខៗហ្នឹង ។

ជិតខាង ៖ យើងថាយើងសព្វថ្ងៃប្រធានក្រុម ក្រុមដូចថាក្តាប់១០គ្រួសារអី ។ ដល់ហ្នឹងគេហៅស្អីត្រង់ណាភ្លេចហើយ ។

ប៊ុនថន ៖ ចាប់ច្រើនទេមីង ចាប់ច្រើនទេ?

ជិតខាង ៖ ចាប់ច្រើនក្រុមគ្រួសារ បើខាងប៉ោយសាវ៉ែងខុសស្អី... ចែខុំ នោះមួយគ្រួសារ វៃទាំងកូនក្រមុំ ទាំងកូនតូចកូនធំទាំងអស់១៣នាក់ ។

ប៊ុនថន ៖ ឈ្មោះអី ឈ្មោះ ខុំ?

ថន ៖ ទេ អ៊ីលុយ ។

ប៊ុនថន ៖ អូ! លុយ?

ថន ៖ ហ្នឹងហើយ ដែលក្រមុំឈ្មោះ ខុំ ។

ជិតខាង ៖ ចាំមើល មីលុយ មីខាម អាភាព អាសុជាតិ អ៊ីវៃ ចែខន អ៊ីភឿ ។

ថន ៖ ដល់ខាងភូមិយើង... អស់មួយពូជ ។

ជិតខាង ៖ អស់១២នាក់ ។

ថន ៖ មួយគ្រួសារគាត់ហ្នឹង ។

ប៊ុនថន ៖ ១២នាក់ហ្នឹង ។ ហើយជិតខាងយើងហ្នឹងគេចាប់ដែរ?

ថន ៖ មួយគ្រួសារហ្នឹងឯង ។

ប៊ុនថន ៖ ពីណាអ្នកចាប់អ្នកមីង?

ថន ៖ មិនស្គាល់វាទេ ខាងពួកគេហ្នឹងឯង ។

ប៊ុនថន ៖ ខាងកងទ័ព ឬឈ្លបគេ?

ថន ៖ ឈ្លបគេមានតូចមានធំ ។

ជិតខាង ៖ ...កាលសម្ងាប់ពួកនោះមិនទាន់មាននិរតីទេ សុទ្ធឈ្លប អត់មានទេ ។

ថន ៖ ពួកទាហានយោធាអី... យោធាស្រុកក្រៅៗដូចស្រុកដងទង់ ។

ប៊ុនថន ៖ អីចឹងចាប់យកទៅណាអ្នកមីង?

ថន ៖ គេចាប់វៃចោលខាងណោះឯង ។

ប៊ុនថន ៖ វៃនៅកន្លែងណាមីង?

ជិតខាង ៖ វៃនៅកន្លែងតាមវាល តាមអី ។

ថន ៖ កាលណាតែចេញពីកន្លែងជម្រកយើងនៅប្រហែលជា ប្រមាណប្រហែលជា៥០ម៉ែត្រដែង វាបាញ់ចោលតែណោះឯងហ្នឹង។ វាអូសយកទៅចោលឯណា។

ប៊ុនថន ៖ ប៉ុន្តែមីងឃើញផ្ទាល់ភ្នែកម៉ង?

ថន ៖ ខ្ញុំបានឃើញតែកូនសំរ៉ាដែលគេបោះ គេយកត្រង់ជំពុះទន់ ចាប់ជើងបោះ យកជំពុះទន់ត្រង់ ត្រង់នោះឯង ផុតអាធំៗគេអូសទៅ។

ប៊ុនថន ៖ ហ្នឹងនៅណា នៅស្រែះហ្នឹង?

ថន ៖ ស្រែះ ដល់គេចម្រាញ់អ្នកដែលមានមុខរបរធ្វើការអស់រួចទៅ បានសេសសល់គេឲ្យមក នៅភូមិវិញ។

ប៊ុនថន ៖ និយាយអីចឹងមីងគេអត់ខ្លាចយើងឃើញទេ?

ថន ៖ ខ្លាចអីបើវាវៃតែនឹងមុខ។ បើកាលខ្ញុំនៅចល័ត គេវៃនឹងមុខ ខ្ញុំគ្រុនញាក់ដេកពេទ្យស្វាយ។

ប៊ុនថន ៖ ចុះក្រៅពីមីងមានអ្នកណាឃើញទៀតទេមីង?

ថន ៖ ពួកម៉ាកខ្ញុំនៅប៉ោយក្លឿងឃើញ។

ប៊ុនថន ៖ និយាយឃើញសម្លាប់មនុស្សអីចឹងណា?

ថន ៖ ពួកម៉ាកខ្ញុំ មីចេក ហ្នឹងស្លាប់ហើយ មីកូនយាយម៉ីនោះស្លាប់ហើយ ចុះមានអ្នកណាទៀត។

ប៊ុនថន ៖ ចុះមីងនៅហ្នឹងមីងធ្វើអីដែរអ្នកមីងនៅស្រែះ?

ថន ៖ មិនទាន់បានធ្វើអីទេនៅហ្នឹង គេមិនទាន់ឲ្យធ្វើអីទេ ដល់ពេលមកនៅភូមិប៉ោយក្លឿងបាន ជ្រើសចល័ត ត្រឹមអាយុ១៨ ១៧អីរើសទៅអស់។ ខ្ញុំមិនដែលបាននៅភូមិទេ ខ្ញុំទៅតែ ចល័ត។ មុនដំបូងលើកទំនប់ស្រែះ នៅរន្ទះបាញ់ ណោះនៅរន្ទះបាញ់។

ប៊ុនថន ៖ នៅប៉ោយក្លឿងបានគេរើសអ្នកមីងចូលកងអ្នកមីង?

ថន ៖ ចាស!

ប៊ុនថន ៖ កាលហ្នឹងអ្នកមីងនៅកងជាមួយអ្នកណាដែរមីង?

ថន ៖ នៅភូមិប្រធានកងមិនដឹងជាអ្នកណាទេ

ជិតខាង ៖ យកឈ្មោះយើងទៅណា ធ្វើការឯឆ្ងាយៗ យើងមានដឹងថាគេឲ្យទៅណាទេ។

ថន ៖ ឲ្យលើកនៅកន្លែងរន្ទះបាញ់ ដល់រួចរន្ទះបាញ់បានទៅណោះទៀត តាប៉ុន ចេញពីតាប៉ុន បានឲ្យទៅណោះ ត្រពាំងថ្ម។

ប៊ុនថន ៖ ចុះមីងប្រធានកងអីមីងមាននៅចាំអត់?

ថន ៖ ប្រធានកងគេនោះ បងសាន់ នោះគេវ៉ៃចោលអស់ហើយ ។

ប៊ុនថន ៖ កាលណោះមីងនៅកង?

ថន ៖ បងសាន់ នោះពីដើមប្រធានកង ដល់ពេលគេចម្រាញ់អាមួយសាយូនហ្នឹង គេថាគាត់ខ្សែយួនគេវ៉ៃចោល នៅអាប្រធានរាយរង់គ្នាឯងថ្មីហ្នឹង ពួក បងរឿ បងអីនៅតាមអ្នកភូមិ ។

ប៊ុនថន ៖ កាលហ្នឹង បង សាន់ គាត់ប្រធានកងអី កងរយ កង?

ថន ៖ កងធំ គេថាគាត់យួន គេយកគាត់វ៉ៃចោល គេមកមួយសាៗ ប្រធានកងធំអីចេះ ដល់ពួកអ្នកក្រោយមកទៀតនេះចម្រាញ់អាពួកនេះទៀត ចម្រាញ់រកយួនរកអីណា សុទ្ធប្រវត្តិថាគាត់នេះយួន យកគាត់ទៅវ៉ៃចោល ។

ប៊ុនថន ៖ ចុះមីងទៅលើកនៅកំបោរស្រះអីអ្នកមីង?

ថន ៖ ចាស! មុនដំបូងហ្នឹងឯង ។

ប៊ុនថន ៖ នៅហ្នឹងគេកំណត់ឲ្យលើកម៉េចដែរមីង?

ថន ៖ ណោះគេលើកធម្មតា លើកថ្ងៃ យើងលើកតែល្ងាចមកវិញទៅ បាយទឹកអីយើង សឹងថាឆ្អែតក៏ឆ្អែត បើអ្នកណាហ៊ានថាមិនឆ្អែតគេវ៉ៃចោលនឹងមុខៗ គេយកទៅធ្វើស្នូលទ្រនាប់ទោះបីថាលំបាកយ៉ាងណា ចេះតែថាឆ្អែតៗពេលប្រជុំទៅ ហូបគ្រប់គ្រាន់ទេ គ្រប់គ្រាន់ ។

ជិតខាង ៖ ហ៊ានថាអត់អ្វី?

ប៊ុនថន ៖ ចុះនៅហ្នឹងគេកំណត់ឲ្យវែកដីមួយថ្ងៃប៉ុន្មានមីង?

ថន ៖ មួយថ្ងៃពីរពេល ។

ប៊ុនថន ៖ មួយថ្ងៃពីរហើយ ហើយមួយថ្ងៃប៉ុន្មានម៉ែត្រអីចឹង?

ថន ៖ អាហ្នឹងអត់រាប់ទេ ។

ប៊ុនថន ៖ អត់រាប់ទេ?

ថន ៖ ចាស! ដំបូងលើកធម្មតាទៅ វែក ។

ប៊ុនថន ៖ រួមគ្នាអ្វីមីង?

ថន ៖ ចាស!

ប៊ុនថន ៖ អីចឹងអត់សូវលំបាកទេមែនទេមីង ដូចថារួមគ្នា?

ថន ៖ ដូចរួមគ្នាទាំងអស់គ្នា ។

ប៊ុនថន ៖ ចុះរបបអាហារម៉េចដែរអ្នកមីងពេលហ្នឹង?

ថន ៖ របបអាហារគេឲ្យហូបចែកគ្នាម្នាក់មួយ ជួនណាទៅបានមួយចាន ជួនណារាងខោចបន្តិចទៅ ។

ប៊ុនថន ៖ ប៉ុន្មានពេលហូប?

ថន ៖ ហូបពីរពេល ព្រឹកមិនទាន់ឲ្យហូបទេ ដល់យើងលើករួចឲ្យធ្វើការសិន ដល់ម៉ោង១០អីបានឲ្យមកហូប ។ ម៉ោង១០សម្រាកបន្តិចទៅ ទៅរែកទៀត ។

ប៊ុនថន ៖ ហើយមីងនៅហ្នឹងនៅប៉ុន្មានខែធ្វើការនៅកំបោរស្រែះ?

ថន ៖ កំបោរស្រែះគ្នាច្រើន សល់យូរ មិនដឹងជាប៉ុន្មានខែ ខ្ញុំភ្លេច មិនសូវចាំទេ ។

ជិតខាង ៖ យូរហើយវាល្មមតែភ្លេច ។

ថន ៖ គ្នាច្រើន ច្រើនយូរ ។

ប៊ុនថន ៖ ប៉ុន្មានមើលទៅ? ច្រើននាក់ដែរមីងក្បាលស្រែះ?

ថន ៖ អូ! រាប់ពាន់ មួយស្រែះចូលមួយកន្លែង ពួកខ្ញុំចូលមួយកន្លែង រន្ទះបាញ់ទៅ ហើយភូមិណាៗក៏នៅរួមទៅ ទាំងអស់គ្នា អត់សូវយូរប៉ុន្មានទេ ហើយមិនសូវបានធ្វើការធ្ងន់ទេ.. ដល់ទៅណោះបានយ៉ាប់មែនទែន នឹកឃើញថាបានរស់ទេទៅណោះ ។

ប៊ុនថន ៖ ស្រែះហ្នឹងទំហំប៉ុន្មានមីងមានចាំទេ ដូចថាប្រវែង បណ្តោយ ជើងក្រោមអី?

ថន ៖ ជើងក្រោមគេប្រហែល៦ម៉ែត្រទេជើងក្រោម បន្ទាប់ពីលើកមកគេឲ្យដាំស្មៅទៅ ដល់ពេលយើងទៅក៏ឈប់ ។

ប៊ុនថន ៖ ហើយប្រវែងប៉ុន្មានមីង?

ថន ៖ ទទឹងប្រហែលជា៥ម៉ែត្រ ។

ប៊ុនថន ៖ ទទឹង៥ម៉ែត្រ ចុះបណ្តោយ?

ថន ៖ បណ្តោយបើពីស្រែះទៅដល់កំបោងណោះ មិនជាប៉ុន្មានគីឡូ ប៉ុន្មានម៉ែត្រ ប៉ុន្តែវាមិនមែនមានតែកន្លែងខ្ញុំលើកទាំងអស់ទេ ដោយភូមិ ។

ប៊ុនថន ៖ ហើយអ្នកមីងចេញពីហ្នឹងទៅណាវិញ?

ថន ៖ ខ្ញុំចេញពីនេះទៅកន្លែងតាប៉ុន ហ្នឹងបានខ្ញុំធ្វើស្រែប្រាំង ។

ប៊ុនថន ៖ បាទ! តាប៉ុន?

ថន ៖ ចាស!

ប៊ុនថន ៖ តាប៉ុនៗ ហ្នឹងនៅម្តុំណាវិញ?

ថន ៖ នៅភ្នំលៀបប្រទាក ។

ប៊ុនថន ៖ ខាងណា?

ថន ៖ ខាងកើតភ្នំលៀបៗ គេហៅតាប៊ុនៗហ្នឹង ភ្នំតាប៊ុន នៅនឹងស្ពានហ្នឹងឯង ។

ប៊ុនថន ៖ ហើយតាប៊ុនហ្នឹងនៅក្នុងឃុំព្រះនេត្រព្រះដែរអ្នកមីង?

ជិតខាង ៖ ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ។

ប៊ុនថន ៖ អូ! ឃុំទឹកជោរ ។

ជិតខាង ៖ ហើយក្នុងមួយស្រុកព្រះនេត្រព្រះវាមានឃុំឈ្នួរមានជ័យ ឃុំជប់វារី ឃុំរហាល ឃុំទានកាំ ឃុំព្រះនេត្រព្រះ ឃុំភ្នំលៀប ឃុំទឹកជោរ ឃុំប្រាសាទ មានប្រាំឃុំមួយស្រុកនេះណា ។

ប៊ុនថន ៖ អីចឹងនៅហ្នឹងមីងប្តូរទៅហ្នឹងនៅឃុំ?

ជិតខាង ៖ ដល់យើងទៅហ្នឹងណា មិនដឹងឃុំអីទេណា អាពតណា ដឹងតែគេថាឃុំ... ។

ថន ៖ ដឹងតែនៅតាប៊ុន ស្ពានហ្នឹងឯង គេធ្វើរោងដាក់ហែៗឲ្យនៅទៅ ។

ប៊ុនថន ៖ ចុះទៅកងមីងប្តូរទៅហ្នឹងទាំងអស់?

ថន ៖ ចាស! ដល់ពេលនៅណោះគេឲ្យលើកភ្លឺតូចៗទៅ បានធ្វើស្រែប្រាំង យប់ឡើងមានការធ្វើឲ្យសែងថ្មមកដាក់ស្ពាន មិនសូវបានដេកទេយប់ឡើងឃ្លានទៅអូសត្រី អូសត្រីបានយកមកចំហុយមិនដឹងមានស្អីចូលជាមួយទេ ឲ្យតែឆ្អិនៗ ដឹងតែហូប តែថ្ងៃណាទេគេឲ្យទៅបើកបានកន្ទក់ម្នាក់មួយចានៗបានកាចឆ្នាំងទៅ នាំគ្នាហូបអានោះឯង ។

ប៊ុនថន ៖ ប៉ុន្តែមានគេកំណត់ឲ្យធ្វើទេមីងមួយ?

ថន ៖ ស្ទូង គេឲ្យស្ទូងធ្វើស្រែប្រាំង យើងអត់សូវនឿយទេ ប៉ុន្តែយើងអត់មានអីហូប បបរសុទ្ធកាលហ្នឹង បបរស្ទីក សេមាន់បេះដាក់បបរឡើងខាប់ ។

ប៊ុនថន ៖ នៅហ្នឹងគេមានកំណត់ម៉ោងអីទេ ធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ថន ៖ ធ្វើព្រឹកដល់ម៉ោង១០គេឲ្យហូបបាយ ដល់ពេលល្ងាចឡើងហូបបាយរួចគេឲ្យទៅរើសថ្មរើសថ្មដែលថ្មដុំធំៗយកទៅដាក់កៀនស្ពាន គេថាអត់ការងារធ្វើ បើឲ្យទៅស្ទូង ស្ទូងមិនត្រង់បន្ទាត់ទេ ហើយបើសិនជាដកសំណាប ដកភាគច្រើនដកដាច់ គេអត់ឲ្យទៅដក ដកទៅវាដាច់ ។

ប៊ុនថន ៖ អីចឹងពិបាកទេការងារហ្នឹង ពេលនៅហ្នឹង?

ថន ៖ ពិបាកត្រង់ហូបហ្នឹងឯង ហូបវាមិនឆ្អែត តែបបរទឹកសុទ្ធ ដល់ឆៀតទៅដកបានពីរថ្នាលបានវែកមក ស្រោសបានជ្រលក់ទឹកប្រហុក ឆ្អែតនឹងអាបន្លែហ្នឹងឯង ។

ប៊ុនថន ៖ ច្រើនទេអ្នកមីងទៅធ្វើការនៅហ្នឹងស្ពាន?

ថន ៖ ស្ពានតាប៉ុន ។

ប៊ុនថន ៖ បាទ! ស្ពានតាប៉ុនហ្នឹងច្រើនទេ ច្រើនគ្នាទេ?

ថន ៖ ច្រើនណាស់ឯង ប៉ុន្តែកន្លែងកងខ្ញុំហ្នឹងកន្លែងស្ងួត ខ្លះគេលើកទំនប់បន្តគ្នាទៅ ប៉ុន្តែខ្ញុំលើករួចមួយកន្លែងហ្នឹងទៅ គេឲ្យស្ងួត អ្នកកងផ្សេងគេលើកនេះទៀត ។

ប៊ុនថន ៖ ចុះកាលហ្នឹងខាងណាអ្នកដឹកនាំវិញអ្នកមីងដូចថាដឹកនាំ?

ថន ៖ អ្នកដឹកនាំមិនដែលស្គាល់គេទេ មិនដឹងគេមកពីណាទេ គេដូរគ្នាសឹងថាមួយខែឃើញផ្សេង ។

ជិតខាង ៖ មួយខែឃើញអ្នកនេះ មួយខែឃើញអ្នកនោះ មិនសូវកំណត់ទេ ។

ប៊ុនថន ៖ ឆ្លាស់គ្នារហូត?

ជិតខាង ៖ រួចដូចថាគេហៅខ្សែត្រៀម គេមិនមែនថានេះទេ គេហៅខ្សែត្រៀមទីមួយ ។

ថន ៖ ខ្សែត្រៀមទីមួយគេ ។

ជិតខាង ៖ រួចទៅក៏មានគេណោះផ្សេង យើងណោះគេបញ្ជូនទៅ កម្លាំងគេចេះតែបញ្ជូនទៅ ប្រធានអ្នកគ្រប់គ្រងនេះផ្សេងគ្នា គ្មានដូចគ្នាទេ ។

ថន ៖ មិនហ៊ានទាំងមើលមុខគេផង ។

ជិតខាង ៖ ឲ្យតែគេរាងធំបន្តិចមិនដែលមើលមុខគេណា ។

ប៊ុនថន ៖ ចុះហ្នឹងដូចថាមានអ្នកដែលធ្វើការ ធ្វើការអត់គ្រប់និយាយថាដែនការគេណា គេកំណត់អីចឹងណា?

ថន ៖ ចុះហ្នឹងត្រឹមគេឲ្យស្ងួត ហើយលៃយ៉ាងម៉េចឲ្យតែត្រង់បន្ទាត់ហ្នឹងទៅ បើមើលពីខាងនេះឲ្យផ្ទុះខាងណោះទៅ មើលពីខាងណោះឲ្យផ្ទុះទៅអីចេះ បើអ្នកណាធ្វើខុសមិនត្រង់បន្ទាត់ទេនោះ គេដកចេញ ។

ប៊ុនថន ៖ ដក មីងដកទៅណាមីង?

ថន ៖ ដកឈប់ឲ្យធ្វើ គេឲ្យសែងថ្មម្តង ។

ប៊ុនថន ៖ ចុះដូចថាមានអ្នកខុសវិន័យខុសអីយកទៅអប់រំ?

ថន ៖ ខុសវិន័យទាល់តែអ្នកលួច ។

ប៊ុនថន ៖ មានដែរ?

ថន ៖ ហូបមិនឆ្អែត ទៅលួចគេ អាហ្នឹងគេយកទៅវ៉ៃចោល ហើយអ្នកខ្លះហ្នឹងមានគេបបរមានគេអីរាងឃ្លានខ្លាំងហ្នឹង នៅកន្លែងទៅលួចរបស់គេ គេវ៉ៃចោល ។

ប៊ុនថន ៖ ប៉ុន្តែមានទេ មានធ្លាប់មានអីចឹងទេ?

ថន ៖ មាន តែច្រើនតែអ្នកដែលមកពីភ្នំពេញ មកពីអីឆ្ងាយៗ ។

ប៊ុនថន ៖ មាននៅចាំឈ្មោះទេមីង?

ថន ៖ ចាំឈ្មោះឯណា បើគេវៃចោលហើយ ឈ្មោះមិត្តយំៗ គេវៃចោលបាត់ ខ្ញុំស្មានតែគេធ្វើលែង គេយកអីវ៉ាន់ យកខោអាវមកចែកគ្នា ស្មានតែគេសម្លុតៗ ដល់ពេលនេះយកទៅវៃមែន ។

ប៊ុនថន ៖ យកទៅវៃ?

ថន ៖ ចាស!

ប៊ុនថន ៖ ឈ្មោះអីគេ?

ថន ៖ ឈ្មោះ យំ អ្នកថ្មីមកពីភ្នំពេញ ។

ប៊ុនថន ៖ មកពីភ្នំពេញ?

ថន ៖ ចាស!

ប៊ុនថន ៖ ស្រី ឬប្រុសអ្នកមីង?

ថន ៖ ស្រី គេយកខោអាវមកចែកគ្នាម្នាក់មួយៗ ។ ខ្ញុំថាចែកខោអាវធ្វើអី យី! គេថាគាត់ទៅវៃចោលហើយ ទុកខោអាវធ្វើអី ។ ខ្ញុំមិនយកទេ ខ្ញុំថាស្មានតែគេថាលេង ឲ្យមីមួយដែលនៅក្បៀនដែលថាផាប់ញឹកញាប់នោះ...។

ប៊ុនថន ៖ យំ ហ្នឹងគាត់ធ្វើអីខុសអ្នកមីង?

ថន ៖ គេថាគាត់ទៅដួសទឹកបបរហ្នឹងឯង ។

ប៊ុនថន ៖ ដួសទឹកបបរហូប ។

ថន ៖ ហើយគាត់នៅឈឺ នៅកន្លែងរោងខ្សោយដូចជាទៅមិនរួចណា គាត់ឃ្លានខ្លាំងគាត់ទៅដួសទឹកបបរ គេថាយើង ។

ជិតខាង ៖ ល្មើស ។

ថន ៖ យើងឈឺសតិអារម្មណ៍ ។

ប៊ុនថន ៖ អីចឹងមីងមានបានឃើញទេគេយកទៅហ្នឹង?

ថន ៖ ទេមិនបានឃើញ គ្រាន់តែឃើញគេយកទៅ មិនបានឃើញគេវៃចោលត្រង់ណាៗអីខ្ញុំមិនបានឃើញ ។

ប៊ុនថន ៖ ប៉ុន្តែក្រោយមកអត់ដែលឃើញ យំ ហ្នឹងមកវិញទេ ។ ចុះអ្នកផ្សេងទៀតមីង ពីណាទៀតមីង?

ថន ៖ គ្មានទេ ខ្ញុំឃើញមួយហ្នឹងឯង ដែលនៅឃុំគ្នា ដេកជុំគ្នាហ្នឹង។

ប៊ុនថន ៖ ចុះអ្នកមីងនៅលើកទំនប់ នៅតាប៉ុន។ តាប៉ុន គេហៅការដ្ឋាន ឬក៏ម៉េចវិញអ្នកមីង?

ថន ៖ គេនៅស្ពាន មិនដឹងស្អីទេ នៅវាលតែម្តង។

ប៊ុនថន ៖ បាទ!

ថន ៖ វាលស្រែ ភូមិគេជិតៗមើលឃើញ ខាងនេះក៏ឃើញ ខាងណោះក៏ឃើញ។ ពួកខ្ញុំនៅតាមទំនប់ដែលគេលើកទៅគេឲ្យធ្វើរោងៗមកទៅ។

ប៊ុនថន ៖ បាទ! មីងទៅនៅហ្នឹងយូរទេមីង?

ថន ៖ ទៅនៅមិនដឹងជាប៉ុន្មានខែទេ ទេមិនដឹងទេ មិនកំណត់ដឹងទេ ប៉ុន្មានទេ ឲ្យទៅនៅ ចេះតែទៅទៅ ដកទៅណា ចេះតែទៅទៅ។

ប៊ុនថន ៖ ចុះចេញពីហ្នឹងទៅមីងទៅណាទៀតមីង ចេញពីតាប៉ុនៗ?

ថន ៖ ចេញពីតាប៉ុនទៅ ខ្ញុំទៅនៅណោះឯង គេហៅត្រពាំងថ្ម។

ប៊ុនថន ៖ ត្រពាំងថ្ម?

ថន ៖ ចាស!

ប៊ុនថន ៖ ទៅច្រើនទេមីង?

ថន ៖ ត្រពាំងថ្មទៅគ្រប់តែគ្នាហ្នឹង ប៉ុន្តែមិនដឹងពួកណាខ្លះទេ។

ប៊ុនថន ៖ ចុះក្រុមមីងទៅទាំងអស់គ្នា ឬមួយម៉េចមីង?

ថន ៖ ក្រុមខ្ញុំខ្លះគេស្ម័គ្រធ្វើពេទ្យ ខ្លះគេស្ម័គ្រធ្វើតម្បាញ ហើយពួកនេះមិនបានទៅណា គេទៅពេទ្យទៅ។

ប៊ុនថន ៖ ចុះមីង មីងទៅ?

ថន ៖ ខ្ញុំមិនចូលទេ គេថាដាច់ខាតគេមិនឲ្យជួបម៉ែជួបឪ ខ្ញុំមិនហ៊ានទៅ គេអ្នកទៅរើស គេថាបើសិនជាចូលខាងតម្បាញ គេមិនឲ្យជួបម៉ែជួបឪទេ ដាច់ខាត គេថាដាច់ខាត ខ្ញុំអត់ហ៊ានទៅ។

ប៊ុនថន ៖ មីងអត់ហ៊ានទៅ មីងទៅកងចល័តណោះមីង?

ថន ៖ កងចល័តរហូត។

ប៊ុនថន ៖ មួយក្រុមមីងប៉ុន្មាននាក់ ទៅណោះមីង?

ថន ៖ ក្នុងក្រុមគេ បើប្រធានកងគេ៣០ មួយក្រុមៗ១០នាក់។

ប៊ុនថន ៖ ពីណាប្រធានកងមីងកាលហ្នឹង?

ថន ៖ មិនស្គាល់គេទេ ។

ប៊ុនថន ៖ អត់ស្គាល់ដែរ?

ថន ៖ គេរើសថ្មីមក វាភ្លេចឈ្មោះណា ខ្ញុំស្គាល់មុខគាត់ម្ដងដែរ កាលខ្ញុំទៅស្រុកស្អីខាងស្នាច់ណោះ ឃើញមុខគាត់ស្គាល់ទៅ ។

ប៊ុនថន ៖ អ្នកស្រុកណាដែរ?

ថន ៖ ជួប ប៉ុន្តែខ្ញុំភ្លេចឈ្មោះគាត់ នៅនឹងស្រុកយើងនេះឯង ស្នាច់នេះ ចាំតែ ម៉ាច កូកី ភ្លេចឈ្មោះគាត់ទៅ មិនដឹងគាត់ឈ្មោះអី ។

ជិតខាង ៖ ឥឡូវជួបគ្នាមិនស្គាល់គ្នាទៀត ។

ប៊ុនថន ៖ មីងចេញទៅហ្នឹងមានចាំទេ ពេលណាវិញមីង ចេញទៅត្រពាំងថ្មហ្នឹង ។

ជិតខាង ៖ អូ! សម័យនោះមិនចាំទេ ។

ប៊ុនថន ៖ បាទ! អត់ដឹងពេលវេលាទេ ។

ជិតខាង ៖ ទេ មិនដឹងថាពេលណាទេ ។

ប៊ុនថន ៖ ប៉ុន្តែទៅដល់ហ្នឹងឃើញមានអ្នកធ្វើការនៅហ្នឹងរួចហ្នឹងនៅមីង?

ថន ៖ គ្មានអ្នកណាទាន់ធ្វើអី មុនដំបូងមានប្រុសៗធ្វើមុនដំបូងចេះទៅ ដល់នេះគេដកទៅណោះទៀតទៅ យើងទៅណោះទៅក្រោយបន្តៗទៀត ។

ប៊ុនថន ៖ អីចឹងទៅដល់ណោះ មីងឃើញប្រុសកំពុងតែធ្វើរួចហើយ ។

ថន ៖ ទេមិនទាន់រួចទេ ។

ប៊ុនថន ៖ អត់ទេ កំពុងតែធ្វើ ចង់និយាយថាទៅនៅមុនណា?

ថន ៖ គេទៅនៅមុនគេធ្វើមួយកំណាត់ទៅ ឧបមាថាក្រោមដើមក្រសាំងទៅអីចេះទៅ ចាប់ពីដើមក្រសាំងទៅ ទៅអីចេះទៅ ខ្ញុំចេះតែទៅរែកទៅមិនដឹងកន្លែង កន្លែងណាមិនស្គាល់គេទេ ។ អត់ចាំបានទេ ។ បើសិនសព្វថ្ងៃនេះគេសួរអត់ដឹងត្រង់ណាទេ ចាំតែកន្លែងត្រពាំងថ្មមួយព្រោះថាអាទៅអីចេះណា ទៅឈរមើលឃើញតែដើមឈើស្វិតៗនេះឯង កាលទៅថ្ងៃមុនណោះ ថ្ងៃទៅសំពោងចុងកាលណោះ កាលទៅជិះឡានទៅ អាស្រែត្រង់នេះដឹងអាហ៍កាលអញលើកទំនប់ អាសាយ គេថាដឹង បើខ្ញុំមិនទាន់កើត ។

ប៊ុនថន ៖ ចុះមីងទៅដល់ហ្នឹង គេឲ្យធ្វើការអីដែរមីង?

ថន ៖ គេឲ្យលើកដី ប៉ុន្តែគេ មុនដំបូងគេឲ្យ២ម៉ែត្រគូប ២ម៉ែត្រគូបកន្លះម្នាក់ ដល់ពេល គេអត់ដាក់ម្នាក់ទេ គេដាក់ពីរនាក់ណោះ៥ម៉ែត្រគូប ដល់ពេលខ្ពស់ៗចុងក្រសាំងនេះបន្ថយនៅពីរនាក់នេះពីរម៉ែត្រ ខ្ពស់វែកធ្ងន់ពេក ទាល់ខ្ពស់ពេកបន្ថយនៅត្រឹមពីរម៉ែត្រ ។

ប៊ុនថន ៖ ហើយមួយថ្ងៃប៉ុន្មានពីរម៉ែត្រគូប?

ថន ៖ ដល់ពេលវាខ្ពស់ជ្រុលពេកទៅ មើលទៅចុងក្រសាំង មើលមកវិញ មិនដឹងជាលើកយ៉ាងណា ។

ប៊ុនថន ៖ ប្រហែលប៉ុន្មានម៉ែត្រកម្ពស់ ប្រហែលណា?

ជិតខាង ៖ ទំនប់នៅនោះ?

ប៊ុនថន ៖ បាទ!

ជិតខាង ៖ កម្ពស់១២ម៉ែត្រ ។

ថន ៖ គ្រាន់តែចុងក្រសាំងមើលមកក្រោម ខ្ញុំដឹងប៉ុន្មានទេ ។

ជិតខាង ៖ មើលគ្រាន់តែយើងមើលមកក្រោមណាស់ គ្រាន់តែគ្នាយើងកាប់ដីនៅក្រោម ដែលវែកឡើងទៅលើនេះ យើងមើលមកក្រោមតូចមួយ ។

ថន ៖ កាប់គន្ធាក់ៗ ធ្វើដូចជណ្តើរអីចឹង ។

ជិតខាង ៖ យើងកាប់គន្ធាក់ៗរាងជណ្តើរណា គេកាប់គន្ធាក់ៗដូចយើងឡើង ។

ថន ៖ សង្ស័យឡើងភ្នំឱរ៉ាល់ទេដឹង ។ ខ្ញុំកុំតែថាមានមិត្តភក្តិជួយហ្នឹង ។

ប៊ុនថន ៖ ឡើងភ្នំឱរ៉ាល់អត់ដែល?

ថន ៖ ខ្ញុំមិនដែលឃើញទេ ឮតែគេថា ។

ជិតខាង ៖ គោងដៃគ្នាហើយ បើសិនជានេះអីអ្នកណាដែលធ្លាក់វិលមុខវិលអីអត់រស់ទេ ចុះបើវារមៀលមកនោះ បន្តិប៉ុនណាណីនោះ ។

ប៊ុនថន ៖ មានដែលអ្នកធ្លាក់ទេអីចឹង?

ថន ៖ ទេដូចមិនដែលឃើញទេ ។ បើមិត្តខ្ញុំមីមួយនោះវាលី លីបន្តិពីរ-បី-បួននោះ រួចគេលីឡើង គេខ្ទាំងៗទៅ... ងាប់ជិនាន់អាពតហ្នឹងឯង ។

ប៊ុនថន ៖ ចុះមីងដល់ពេលខ្ពស់អីចឹង មីងវែកឡើងរួចទេមីង?

ថន ៖ ខ្ញុំថាខ្ញុំវែកឡើងមិនរួចទៅ មិត្តខ្ញុំនៅប៉ោយពីអ្នកវែក គេមាឌរាងធំនោះ គេវែក ខ្ញុំអ្នកកាប់ហើយពីរនាក់ទៀត ។

ជិតខាង ៖ មកកាយដាក់ឲ្យគេទៅ យើងកាប់កាយៗ ។

ប៊ុនថន ៖ អីចឹងពីរម៉ែត្រគូបហ្នឹងពីរនាក់?

ថន ៖ ចាស!

ជិតខាង ៖ គេត្រូវឲ្យមានគូអីចឹងឯង ។

ថន ៖ កាលមុនដំបូងដែលទាបហ្នឹងពីម៉ែត្រកន្លះ ។

ជិតខាង ៖ ដល់អាដើមកាំជ្រួចទៅលើហ្នឹង បានគេឲ្យពីរម៉ែត្រគូប ។

ថន ៖ ប៉ុន្តែទៅហ្នឹងគេឲ្យ ។

ប៊ុនថន ៖ អីចឹងពីរម៉ែត្រគូបហ្នឹងគេឲ្យពីរនាក់ចែកគ្នាៗ?

ថន ៖ ប្រាំម៉ែត្រគូប ។

ប៊ុនថន ៖ ប្រាំម៉ែត្រគូប?

ជិតខាង ៖ ពីរនាក់ហ្នឹងប្រាំម៉ែត្រគូប ពីរនាក់ដឹងតែពីរម៉ែត្រគូបកន្លះណាអូនឯងស្តាប់បានទេ ពីរនាក់ហ្នឹងដឹងតែពីរម៉ែត្រគូបកន្លះ ។

ថន ៖ ក្នុងម្នាក់ពីរម៉ែត្រគូបកន្លះ ។

ជិតខាង ៖ អូ! ក្នុងម្នាក់ពីរម៉ែត្រគូបកន្លះ ពីរនាក់នោះគេឲ្យដាក់យើងត្រូតពីរនាក់នេះគេឲ្យប្រាំម៉ែត្រគូប ។ អីចឹងមួយយើងនៅត្រូវកាយដូចថាមើលមាឌយើងខ្លាំង យើងមានកម្លាំងដូរគ្នាទៅណា វាអីចឹងឯង តែបើប្រុសៗ ។

ថន ៖ ដូចមិនមែនដូរ ។

ប្រុញ ៖ កាន់តែខ្ពស់នៅសល់ពីរម៉ែត្រ ។

ថន ៖ វាចេះតែខ្ពស់ខ្លាំងពេក គេឲ្យនៅ... គ្នាពីរនាក់នេះវាបួនម៉ែត្រ បួនម៉ែត្រមានជីល្វាចរួច ។

ជិតខាង ៖ ដូចមិនមែន១២ទេ ២៤អ្វី កម្ពស់ ដូចរាងយូរពេក ។

ថន ៖ កម្ពស់ប្រហែល១២ម៉ែត្រហ្នឹងឯង ខ្ពស់ប៉ុនចុងក្រសាំង កម្ពស់ត្រឹមចុងទឹកដោះគោនេះឯង ។

ជិតខាង ៖ យើងលើកនេះ មើលតែចុងក្រសាំងវានៅក្រោម វានៅៗជាមួយដីទំនប់ណា នៅក្រោមដល់ពេលចុងក្រសាំងវាមិនឡើងទៅអីចេះ ដល់ទំនប់នេះវាស្មើនឹងណោះដែរ ។

ប៊ុនថន ៖ ចុះបាតៗ និយាយថាបាតក្រោមទំនប់ប៉ុន្មានមីង?

ថន ៖ អត់ដឹងទេ មិនដែលដឹងថាប៉ុន្មានទេ ដឹងតែកម្ពស់រាងធំ ដឹងតែរែកចាក់ៗ ដឹងតែ... រឿងគិតតែខំឲ្យតែរួច ។

ជិតខាង ៖ ដល់ពេលរួច គេធ្វើមីទ្ទីងម្តង ។

ថន ៖ មីទ្មិងគេមិនដឹងមីទ្មិងអីទេ ។

ប៊ុនថន ៖ ចុះមីងរបបអីម៉េចដែរ?

ថន ៖ អាហ្នឹងគេឲ្យហូបបរិបូរ ព្រឹកគេឲ្យក្រោកហូបបបរ ហូបបបរ ប៉ុន្តែខ្ញុំអត់ងងុយ ខ្ញុំសុខចិត្តដេក ខ្ញុំមិនក្រោកទៅហូបទេ គេមកហូបបបរ ខ្ញុំដេកបានយូគ្រាន់ ខ្ញុំបើសិនជាអត់ងងុយវិលមុខ ខ្ញុំសុខចិត្តអត់ព្រឹក ។

ប៊ុនថន ៖ ចុះពេលថ្ងៃ?

ថន ៖ ពេលថ្ងៃហូបបាយ ។

ប៊ុនថន ៖ ល្ងាច?

ថន ៖ ល្ងាចក៏បាយ អាហ្នឹងហូបឆ្អែត ប៉ុន្តែធ្វើការផាវយ៉ាប់ ។

ប៊ុនថន ៖ ចុះធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានពេលព្រឹកមីង?

ថន ៖ ពីព្រឹកក្រោកតាំងពីម៉ោងបីព្រឹកឲ្យទៅហូបបបរ ឲ្យតែហូបរួចហើយចែកគ្នាចេញ ។

ប៊ុនថន ៖ ហើយរហូតដល់ម៉ោងប៉ុន្មានមីង?

ថន ៖ ថ្ងៃម៉ោង១១ហូបបាយ ។

ជិតខាង ៖ រួចមិនរួចយ៉ាងណាត្រូវតែមកហូបបាយ ។

ថន ៖ យើងចង់រួចយើងមិនបាច់ឈប់ ហូបតែបាយរួចកាប់ទៀតទៅ បើយើងសល់ច្រើន យើងខ្លាចមិនរួចមកវិញភ្លាម ។

ជិតខាង ៖ បើសិនជាដល់នេះគេ គេចាំម៉ោងមួយ គេកំណត់គេណា យើងឲ្យយើងសម្រាកចំនួនមួយម៉ោង ។

ប៊ុនថន ៖ ម៉ោងមួយល្ងាចដល់ម៉ោងប៉ុន្មាន?

ថន ៖ ល្ងាចស្រេចតែយើងរួច ។

ជិតខាង ៖ ចុះបើមិនរួច បើរួចម៉ោងបីគេមកមុនយើង គេកំណត់ម៉ែត្រគូបឲ្យយើងហើយ គេកំណត់ម៉ោងធ្វើអី ។

ប៊ុនថន ៖ អីចឹងគេអត់កំណត់ម៉ោងទេ?

ជិតខាង ៖ ទេ អត់មានកំណត់ម៉ោងទេ ។

ថន ៖ ក្នុងបួនម៉ែត្រហ្នឹងបើសិនដល់ទួលខ្ពស់ហ្នឹង ក្នុងបួនម៉ែត្រធ្វើម៉េចឲ្យរួច មើលតែយើងរួចហើយ យើងមិនទាន់ហ៊ានខំឲ្យរួចមុនគេ យើងធ្វើលែង១ ធ្វើនៅចាំគេ ។

ជិតខាង ៖ ធ្វើរួចមុនគេក៏ខុសទៀត ។

ប្រុញ ៖ តែអាខ្ពស់ផុតតែម្នាក់ពីរម៉ែត្រទេ?

ថន ៖ ចាស! ពីរម៉ែត្រ ។

ប្រុញ ៖ អីចឹងពីរនាក់ប្អូនម៉ែត្រហើយ?

ថន ៖ ពីរនាក់ដឹងតែប្អូនម៉ែត្រ ។

ប៊ុនថន ៖ ចុះមីងដូចធ្វើអីចឹងមានអ្នកដែលធ្វើអត់ហើយ?

ថន ៖ ដូចមិនសូវមានទេ អ្នកធ្វើអត់ហើយមិនមានទេ មានតែអ្នកខុសមាត់ គេហៅថាករណី ដូចជាអ្នកធ្វើការនៅភ្នំពេញនៅអី មនុស្សប្រុសៗគាត់រាងស្អាតៗ គាត់ឃើញហូបបាយ ព្រោះឃើញម្ហូប គាត់និយាយថា បានប្រហែលបបរជ្រូកអញពីសង្គមទេ មានខុសទៀត យកទៅវៃចោល ។ មាន ចាស! មាន ។

ប៊ុនថន ៖ នៅកងជាមួយមីងដែរ?

ថន ៖ ប៉ុន្តែបើនៅជិតខ្ញុំទៅ ។

ជិតខាង ៖ កងមនុស្សប្រុសគេដាក់ ។

ថន ៖ ដាក់តាមប្រុសៗផ្សេង ។

ជិតខាង ៖ ស្រីគេដាក់តែកងស្រីទេ ។

ប៊ុនថន ៖ ប៉ុន្តែម៉េចបានមីងដឹង?

ថន ៖ ចុះបើក្នុងមួយកងធំរាឡើង៧នាក់នោះ ។ អូន! មួយកងគ្នាច្រើននាក់ ហើយនៅជិតគ្នា ។

ជិតខាង ៖ អាអូនឯងប្អូនខ្ញុំអីចឹងទៅណា ។

ថន ៖ ពួពីមួយទៅមួយ...មានអ្នកនិយាយចេញទៅ ។

ជិតខាង ៖ ដូចថាអូនឯងពីរនាក់នេះប្អូនខ្ញុំបង្កើតចឹងណា ខ្ញុំនេះបង បងស្រីបង្កើតណាអត់ហ៊ានមកសួរ បងទេណា លើកទំនប់គ្រាន់តែកងធំនៅជាមួយគ្នាណាអូន ឯងលើករួចអីចេះ ហ៊ានមកអើត ឡើមៗអីចេះមិនហ៊ានមកសួរបងទេណា ទាល់តែគេស៊ើបប្រវត្តិដឹងច្បាស់ថាប្អូនបង្កើតណា បានអាចមកជួយអីបាន អត់មកហ៊ានមក ។

ប៊ុនថន ៖ ចុះមីងនៅហ្នឹងដូចមានអ្នកឈឺអ្នកអីទេអ្នកមីងធ្វើការច្រើន?

ថន ៖ ឈឺ គេឲ្យថ្នាំលេប ។ ឲ្យអាថ្នាំស្អីគេនោះ ឱសថបុរាណខ្មែរ ។

ប៊ុនថន ៖ លេបថ្នាំហ្នឹងទៅជាទេអ្នកមីង?

ថន ៖ អ្នកណាទៅក៏ជាទៅ អ្នកណាទៅ គេឲ្យមកដេកពេទ្យហ្នឹង រហាល គេហៅឃុំរហាល ។

ប៊ុនថន ៖ ឃុំរហាល ។

ថន ៖ ដេកពេទ្យឃុំ ។ ថ្នាំប៉ុនៗនេះ ។ ខ្ញុំកាលណោះនៅវន្ទះបាញ់ដេកពេទ្យម្ដងដែរ ដេកពេទ្យរហាល ដេកពេទ្យរហាលម្ដង ។

ប៉ុនថន ៖ ឈឺអីគេវិញកាលហ្នឹងអ្នកមីង?

ថន ៖ គ្រុនញាក់ម្ដង ។ ញាក់ទៅនៅហាលភ្លៀង ទឹកសន្សើម ញាក់ ញាក់យូរវាញាក់មិនបាត់ ។

ប៉ុនថន ៖ ហើយមកដេកពេទ្យនេះជាទេអ្នកមីង បានជាទេអ្នកមីង?

ថន ៖ ដេកពេទ្យនេះគេឲ្យថ្នាំលេប ។

ជិតខាង ៖ ហើយម៉ែឪយំរហេមរហាម ។

ថន ៖ ជា ដល់ពេលជាមិនបានទៅកន្លែងវិញទេ ខ្មោចតាខ្ញុំគាត់ទៅយក យកមកនៅភូមិវិញ មកនៅភូមិមឿង គាត់សន្តមកិច្ចណា គាត់ធ្វើសន្តមកិច្ចទៅក៏សុំច្បាប់គេទៅយក ដាក់ថ្នាំខ្មែរទៅបានជា ។

ប៉ុនថន ៖ ហើយអ្នកមីងនៅត្រពាំងថ្មហ្នឹងរយៈពេលប៉ុន្មានអ្នកមីង ទៅធ្វើនៅត្រពាំងថ្ម ច្រើនខែទេ?

ថន ៖ ច្រើនខែ ។

ជិតខាង ៖ មិនដែលបានរាប់ខែទេ ។

ថន ៖ ដឹងតែច្រើន ចុះវាយូរ ទំនប់វាខ្ពស់ ។ គ្រាន់តែដឹងថាដល់ពេលចេញហ្នឹងទៅ បានដឹងថាទៅកូនខ្វែង ។

ប៉ុនថន ៖ នៅត្រពាំងថ្មហ្នឹង អ្នកណាអ្នកគ្រប់គ្រងអ្នកមីង?

ថន ៖ ប្រធានគេមិនដឹងអ្នកណាមកពីណា ឈ្មោះ តាផន តាអីណា បើប្រធានធំគេនោះឈ្មោះតាផន បើកន្លែង បើប្រធានធំគេនោះឈ្មោះតាផន បើកន្លែងស្អីទៅកូនខ្វែងឈ្មោះតាវ៉ាល់ តាម៉ោងហ្នឹងឯង ។

ប៉ុនថន ៖ អីចឹងនៅត្រពាំងថ្មហ្នឹងឈ្មោះ តាផន?

ថន ៖ ចាស!

ប៉ុនថន ៖ តាផនហ្នឹងគាត់ធ្វើអីដែរអ្នកមីង មានដឹងតំណែងទេ?

ជិតខាង ៖ ដឹងអី ដឹងគេប្រធាន ។

ថន ៖ ឮគេថាលើកដៃៗអឺចេះ នោះប្រធានមកហើយ

ជិតខាង ៖ ប្រហែលស្ដេច ។

ថន ៖ គ្មាននរណាហ៊ានឈប់ទេ ។

ជិតខាង ៖ ដូចថាយើងទៅមិនរួចហើយ ឮតែគេមកហើយ ទៅទៀតទៅណា ។

ប៊ុនថន ៖ ផន ហ្នឹងមិនមែនអ្នកស្រុកព្រះនេត្រព្រះទេ?

ជិតខាង ៖ វ៉ាល់ ហ្នឹងក៏មិនដឹងនៅឯណា ។

ថន ៖ ឮតែឈ្មោះគេថា ។ តាវ៉ាល់ វាងស្ដើង ។

ប៊ុនថន ៖ អ្នកមីងចេញមកពីហ្នឹងមកកូនខ្វែងទៀតអ្នកមីង?

ថន ៖ ចាស! កូនខ្វែង... ។

ប៊ុនថន ៖ កូនខ្វែងនៅម្ដុំណា?

ជិតខាង ៖ កូនខ្វែងនៅហួសណាំតាវ ។

ថន ៖ ទៅឃើញតែដើមឈើ ដើមព្រៃ ឃើញព្រៃ ឃើញភ្នំ ។

ជិតខាង ៖ ព្រៃកូនខ្វែង គេថាជាប់ ដូចខ្ញុំទៅដល់កាត់ឫស្សី ខ្ញុំអត់ដឹងទេ ឮគេនិយាយសព្វថ្ងៃហ្នឹង ថាព្រៃកូនខ្វែងជិត ជាប់តែព្រំដែនហ្នឹង ។ កូនខ្វែងដែលមួយសាដែលកាលវៀតណាមចូល នោះ គេមិនកៀរអ្នកនៅកូនខ្វែងទៅត្រង់ណោះឯង ទៅលើភ្នំ ។

ថន ៖ ភ្នំកូនខ្វែង ភ្នំគេណោះឯង ។

ប៊ុនថន ៖ អីចឹងមីងទៅនៅភ្នំកូនខ្វែងទៀត?

ថន ៖ ចាស! ទៅនៅភ្នំកូនខ្វែងនោះ មិនសូវយូរទេ ព្រោះវាអត់ទឹកពេក គេឆាប់ឲ្យមកវិញ ។

ប៊ុនថន ៖ ច្រើនទេអ្នកមីងបញ្ជូនទៅលើកនៅកូនខ្វែងហ្នឹង?

ថន ៖ អូ! និយាយពីរកៈ មើលខាប់ទាំងទឹក ខាប់ទាំងអី ។

ជិតខាង ៖ កាលកន្ទួចទៅកូនខ្វែងហ្នឹងដឹង បានកងអញវិណាំតាវណោះ ។

ថន ៖ ខ្ញុំទៅកូនខ្វែង ។

ជិតខាង ៖ ហ្នឹងឯង កងវាទៅកូនខ្វែង កងខ្ញុំនៅវិណាំតាវ ។

ថន ៖ មានអ្នកលេបថ្នាំគ្រាប់ស្វែងងាប់អស់ម្នាក់ មានអាបងនោះពស់ចឹកហើយ ប្អូនខឹង មិនចង់ដឹងថាបងងាប់ហើយក៏លេបអាគ្រាប់ស្វែងហ្នឹងងាប់ ។ លេបគ្រាប់ស្វែងមួយក្ដាប់ មកដល់ស្នានតែ រើសធ្វើអី រើសបានងាប់ កាប់ជាពីរជាបី១ ដឹកទឹកបបរ១ ក៏ដេកដណ្ដប់ភួយព្រឹកឡើងគេដើរមកធ្វើការ ធ្វើការឯណា រឹងឆ្អិត ។

ប៊ុនថន ៖ គាត់និយាយអ្នកដែលពស់ចឹកហ្នឹង អ្នកដែល?

ថន ៖ បងគាត់១ ។ ប៉ុន្តែមិនពួកប្រជាជនស្រុកយើងនេះទេ គេសុទ្ធតែពួកអ្នកថ្មីមកពីឆ្ងាយ១មក នៅជុំគ្នា ភាគច្រើនពួកអ្នកភ្នំពេញច្រើនតែហើម បើពួកខ្ញុំមិនដែលបានហើមទេ តែស្គម ស្គមជាប់ឆ្អឹង ។

ជិតខាង ៖ សល់ស្បែកដណ្ដប់នឹង។

ថន ៖ ហ្នឹងឯង។ ភាគច្រើនហើមមិនសូវមានរស់ទេ។

ជិតខាង ៖ ពេលខបមាថា យើងចាប់មុខព្រួញមួយៗដែលបានមក ម៉ែឪបងប្អូននេះសុទ្ធតែឃំ ឃើញមុខ។

ថន ៖ ខ្ញុំដល់ពេលវៀតណាមចូលហូបបាយមិនដែលបានទេ ហូបតែបបរ ក្រពះអត់កិនសោះ ម្ហូបអត់កើតសោះ បាយអាណាគេ។

ប៊ុនថន ៖ ចុះអ្នកមីងទៅកូនខ្ទែងហ្នឹងមានកំណត់ឲ្យធ្វើ?

ថន ៖ អត់ទេ កូនខ្ទែងដូចអត់មានកំណត់ឲ្យធ្វើទេ។

ជិតខាង ៖ កូនខ្ទែងរែកដីដូចតែគ្នា

ជិតខាង ៖ រែកប៉ុន្តែមិនដឹងម៉េច ទំនប់នោះវាទៅត្រូវទៅចុះវិញ។

ថន ៖ សាមុត នោះវាអត់ទឹកមិនបាន តាវ៉ាល់ មកក៏សួរថាមិត្តឯងធ្វើម៉េច ក្រោកមកស្រែកអស់សន្ទឹង។ យី! ទឹកច្រោះមិនមាន ផាប់បានតែផាប់ទៅ ស្មានតែខ្លាច នេះគាត់ថាចេះ នេះដូចថាខ្ញុំកាប់ឲ្យវា ចុះដេកជុំគ្នាហ្នឹង ខ្ញុំញ័រអស់ហើយ... វ៉ៃក៏វ៉ៃទៅអញស៊ូមិនបានទេ។

ប៊ុនថន ៖ ពីណាៗ?

ថន ៖ មុត ហ្នឹង។

ប៊ុនថន ៖ អូ! គាត់នៅរស់ទេ?

ថន ៖ នៅរស់តើស តែខ្លាចតែគេ...។

ប៊ុនថន ៖ ឈ្មោះអីគេ?

ថន ៖ មុត។ សួស សាមុត។

ជិតខាង ៖ មិនមែន សាមុត នេះទេ មុត ម៉ែមី។

ថន ៖ ទេប្អូនថៃ។

ជិតខាង ៖ ប្អូន...។ ប្រុស សាមុត អត់នៅទេ។ សាមុត វាទៅថៃហើយ។

ថន ៖ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែ សាមុត នេះឯង។

ជិតខាង ៖ មី សាមុត មាឌខ្ពស់គក្រោង។

ប៊ុនថន ៖ ចុះៗគាត់ស្រែកឲ្យ?

ថន ៖ ស្រែកឲ្យប្រធានធំ ប្រធានធំ គាវ៉ាល់ ហ្នឹង ចុះចាំប្រធានធំយកទៅ។ ចុះមិត្តអើយបើយ៉ាប់អីចឹងក៏សម្រាកទៅ ចាំទឹកគេមក ទឹកគេក្នុង១០នាក់ហ្នឹង គេឲ្យអ្នកទៅវែកម្នាក់។ ខ្ញុំឯងគេឲ្យធ្វើប្រធានក្រុម។

ប៊ុនថន ៖ ក្នុងចាទឹកអ្វី។

ជិតខាង ៖ ក្រុមដូចថាមួយក្រុមយើងអីចឹង... ដូចថាម្នាក់នេះទៅវែកទឹកអីចេះ ខ្ញុំនេះទៅជួយកាប់គេទៅណោះទៅជួយគេ មិនមែននេះឯណា។

ប៊ុនថន ៖ វែកបានមួយម្នាក់ប៉ុន្មាន?

ថន ៖ វែក គេវែកមក។ ចុះគេវែកមានកាមែល មានកាដុងតូចៗ ទៅមួយដបបាន...មួយពេងៗ សុទ្ធតែគ្រប់គ្នាទាំងអស់ ហើយសល់រំលែកគ្នាទៀត។ ដល់ពេលហូបបាយ ទៅវែកបីដងក្នុងមួយថ្ងៃ ឲ្យតែនារីហ្នឹងឯងទៅវែក។

ជិតខាង ៖ ...ចៃរីន ចៃរ៉ែន ធ្វើអស់ ប្រពន្ធដុកឌ័រ ជឿន នោះ។

ថន ៖ រ៉ែន នោះប្រធានកង រ៉ែន ប្រធានកង។

ជិតខាង ៖ រ៉ែន ហ្នឹងគេសមប្រធានកង គេធ្វើអស់ហើយ ពួកនោះឡើងធ្វើអស់ហើយ។

ប៊ុនថន ៖ អីចឹងអ្នកមីងនៅកូនខ្វែងហ្នឹងយ៉ាប់ទឹកជាងនៅត្រពាំងថ្មទៀត?

ថន ៖ ទុកទឹកមួយកាមែលក្បាលដេកហ្នឹង អ្នកដែលគេឃើញទឹកហ្នឹង គេរាយការណ៍ថាខ្ញុំលាក់ទឹកដឹកតែឯង ដល់ពេលកូនក្រុមទាំងអស់គ្នាហ្នឹងថា គាត់មិនមែនលាក់ទុកតែឯងទេ គាត់លាក់ទុកចែកគ្នាលុបមុខព្រឹក នេះបាន កុំអីគេវៃចោលកាលណោះហើយ។ ហូបបាយរួចគាអៅ សុទ្ធតែចៃ មានអាវប៉ុន្មានពាក់ឡើងអស់ ចុះមានទឹក។

ប៊ុនថន ៖ ចុះរបបអាហារអីម៉េចដែរមីង?

ថន ៖ ទេបើបាយគេឲ្យហូបត្រឹមត្រូវ ប៉ុន្តែអត់ទឹក។

ប្រុញ ៖ អត់ទឹកផ្ទូតអី?

ថន ៖ អត់ទឹកផូត អត់ទឹកហូបទាំងអស់នេះឯង។

ប្រុញ ៖ ប៉ុន្មានខែបានផូតទឹកម្តងអីចឹង?

ថន ៖ អូ! យ៉ាប់ណាស់ រកម៉ែ រកអីមិនឃើញទេ ទឹកដឹងតែគេហៅទៅ មិនដឹងថាថ្ងៃណា ខែណា ថ្ងៃណា ចេះតែហៅ ចេះតែទៅ ដល់ពេលគេថា អូ! យ៉ាប់ខ្លាំង គេដកឲ្យទៅណោះទៀត។

ប៊ុនថន ៖ ដកចេញទៅណាទៀតមីង?

ថន ៖ ដកមកពីណោះគេឲ្យមកស្ទូងស្រូវទៅ វិលទៅកន្លែងចាស់វិញ ។

ជិតខាង ៖ កន្លែងកាប់ដីស្គាល់ច្រើនជាងកន្លែងស្ទូងស្រូវ ប៉ុន្តែគេបញ្ជូនយើងមិនដឹងទៅណាអូន ឧបថា រួចខ្សែត្រៀមនេះហើយ គេបញ្ជូនយើងទៅណោះទៀត ចុះយើងសុទ្ធតែអ្នកកម្លាំងណោះ កម្លាំងទីមួយ ។

ប៊ុនថន ៖ អ្នកមីងដូចអត់ទឹកអីចឹងមានអ្នកឈឺមានអ្នកអីដែរអត់មីង?

ថន ៖ មានៗអ្នកឈឺទេ មានគ្រូពេទ្យមានអី ។

ប៊ុនថន ៖ បាទ! ច្រើនទេមីង ឈឺច្រើនទេអ្នកមីង?

ថន ៖ ហ៊ឺ! ឈឺឡើងរកមនុស្សធ្វើការមិនបាន ដល់មើលទៅយ៉ាប់ខ្លាំងទៅ ដកមកវិញ ដកមកស្ទូង ។

ប៊ុនថន ៖ ប៉ុន្តែអ្នកឈឺភាគច្រើនឈឺអីវិញមីង?

ថន ៖ ឈឺអីឈឺតែគ្រុនញាក់ហ្នឹង ដូចចាញ់ទឹកចាញ់ដី ជំនឿវាមាន ។

ជិតខាង ៖ កម្តៅថ្ងៃវាខ្លាំងទៅ យើងអត់មានទឹកផ្ទូត... ។

ថន ៖ ...ព្រឺៗ ញាក់ៗគ្រប់តែគ្នា ។

ជិតខាង ៖ សំណាងហើយបានកើតសម័យនេះ បើកើតសម័យនោះជាមួយមីងស្រួលជាងហ្នឹង ។

ថន ៖ ទេខ្ញុំសំណាងហើយដែលមិនងាប់ ។

ប៊ុនថន ៖ តែមានអ្នកឈឺដល់ថ្នាក់ស្លាប់អីដែរអត់អ្នកមីង?

ថន ៖ អូ! ច្រើនណាស់ ។

ប៊ុនថន ៖ កងមីងអីមានស្លាប់ទេជាមួយមីង?

ថន ៖ មាន អ្នកស្លាប់មួយកំប៉េះ ប៉ុន្តែខ្ញុំមិនចាំទេ ភូមិគេនៅឆ្ងាយៗពីគ្នា តែដល់គេត្រង់ណោះទៅហើយ វាមិននឹកឃើញទៀត ។

ជិតខាង ៖ កាលណោះនៅក្មេងៗ ។

ថន ៖ ហ្នឹងឯង មិនសូវបានគិតគូរទេ ។

ជិតខាង ៖ ដោយសារប្រៀបមិនបានថា អានាងឯងប្រុសអីចេះនៅជាមួយគ្នា ជម្លៀសទៅជាមួយគ្នា អានាងឯងមិនសូវស្គាល់ខ្ញុំ ខ្ញុំមិនសូវស្គាល់អានាងឯង មិនមែនថាមិនស្គាល់ទេ ស្គាល់បើយើងនិយាយជាមួយគ្នាខ្លាច មិនមែនមិនស្គាល់ទេ បងស្ងួរពេទ្យមិនហ៊ាននិយាយផង ។

ថន ៖ អ្នកថ្មី..ខ្លាចគេស៊ើបប្រវត្តិទៅ ខ្លាច ជ្រុលមាត់ជ្រុលកនិយាយថា នែ! ម៉ែឪខ្ញុំពីដើមមិញនៅភ្នំពេញនៅអីអីចេះទៅ ធ្វើការធំអីទៅ គឺមានអាអ្នកជិតខ្លួនឯងហ្នឹងគេឲ្យដាក់ធ្វើប្រធាន

កង ប្រធានពួកហ្នឹង ក្នុងមួយក្រុមមានបីនាក់ ស៊ើបគ្នាបីនាក់ហ្នឹងឯង ។ ទៅគេរាយការណ៍ប្រាប់គេចង់បានមុខបានមាត់ទៅ គេរាយការណ៍ប្រាប់ទៅ យប់ឡើងទាញគ្នាទៅវ៉ៃចោលទាំងយប់ទៅ ។

ប៊ុនថន : ពីណាមីង?

ថន : នោះនៅកន្លែងដើម-គបីដើមអាដួវទៅភ្នំស្រុក ។

ជិតខាង : អានាង ឯងស្គាល់ទេដើម-គបីដើម?

ប៊ុនថន : ដើម-គខ្ញុំធ្លាប់ឮឈ្មោះ ។

ជិតខាង : នែ! ដើម-គបីដើម គិតទៅវាចិញ្ចាំយើងសព្វ ឲ្យចេញអាខ្សែត្រៀមទីពីរ ទីមួយអាខ្សែត្រៀមខាំង កូនខ្វែងណាំតាវ កំពីងពួយហើយ គេឲ្យយើងចេញមកអាដើម-គបីដើម ។ ដើម-គបីដើមងាប់ច្រើនណាស់ ។

ប៊ុនថន : អីចឹងមីងចេញពីកូនខ្វែងនេះមកដើម-គបីដើម ។

ថន : ដើម-គបីដើមប្រចាំការរហូត ។ មិនទាន់ប្រចាំការទេ រហូតមកដល់ដើមចាស់ គាប៊ុនវៀតណាមចូល ។

ប៊ុនថន : ដើម-គបីដើមហ្នឹងមីងមកធ្វើអីវិញមីង?

ថន : លើកទំនប់នេះឯងវិញ ប៉ុន្តែមិនធូនប៉ុន្មានទេ ឧបមាគេកាប់អីចេះបីដើមធំៗអីចេះទៅដាក់បន្តគ្នាកន្លែងទំនប់នេះ ។

ជិតខាង : ...តម្រៀបជួរគ្នាណា ។ នោះគេធ្វើស្រែប្រាំង បើយើងគេថាធ្វើភ្លឺស្រែប្រាំងសព្វថ្ងៃណា បើគេនោះថាភ្លឺខាត់ខ្វែងគេ នោះយើងគិតតម្រៀបជួរគ្នានោះមិនសូវអត់ទេ ។

ប៊ុនថន : អត់មានកំណត់អត់មានអីទេ?

ថន : ចាស!

ជិតខាង : មិនដែលដឹងថាថ្ងៃប៉ុន្មានៗអីទេ ។

ថន : ទ្រុឌទ្រោមខាំងទៅមកធ្វើអីចុះនៅកូនខ្វែងហ្នឹង ។

ជិតខាង : អានេះវាខ្សោយហើយ គេដឹងថាយើងមិនកើតហើយ ។

ប៊ុនថន : ប៉ុន្តែគេអត់មានកំណត់ឲ្យធ្វើប៉ុន្មានៗអី?

ថន : អត់ទេ អាហ្នឹងដឹងតែធ្វើរួមយប់ផង ថ្ងៃផង?

ប៊ុនថន : យប់ដល់ម៉ោងប៉ុន្មានមីង?

ថន : យប់ថ្ងៃណាម៉ោង៩ទៅ ជួនណាម៉ោង១០ទៅ មកវិញហើយមិនដេកទៀត ។

ប៊ុនថន ៖ ហើយរបបៗមីង?

ថន ៖ របបបបរស្ងុទ ខ្ញុំខ្វចក្រពះអស់ ។

ប៊ុនថន ៖ នៅគ-បីដើម?

ថន ៖ ចាស! បបរមានខាប់មានរាវ ។

ជិតខាង ៖ ទៅហ្នឹងខ្មែរត្រៀមទីមួយគេអត់លាយអីទេ គេបបរឲ្យស្ងុទដែរ ។

ថន ៖ បបរស្ងុទមិនដែលមានម្ហូបទេ បើក្រៅពីសម្លរព្រលិតហើយ សម្លរទឹកប្រហុក សម្លរទឹកប្រហុកបេះទឹកស្អី ស្អីមីឈ្នាងមាន់នោះ មានត្រកួនឲ្យតែមានបេះដាក់សម្លរទាំងអស់ បេះលាយក្នុងបបរមួយចានដាក់លាយឡើងខាប់ច្រើនអីចេះទៅស្អែត ។

ជិតខាង ៖ នែ! ដែលស្គាល់អាត្រួយដង្កៀបក្តាមទេ?

ប៊ុនថន ៖ ស្គាល់តើសមីង ។

ជិតខាង ៖ ត្រួយដង្កៀបក្តាបភ្លោះមកមិនទាន់ទេ ។

ប៊ុនថន ៖ ចុះមីងនៅគ-បីដើមហ្នឹងចេញពីហ្នឹងមកទៅណាទៀតមីង?

ថន ៖ ចេញមកទៅតាប៉ុន ទៅស្នួងនោះឯង ដល់ពេលវៀតណាមចាប់ វៀតណាមចូលបណ្តោយ ។

ជិតខាង ៖ មកក្រោយខ្ញុំតើស ខ្ញុំមកបានឡើងបួនថ្ងៃបានវាបាន ដល់គេថាងាប់គ្រប់គ្នា ចុះបើវាបញ្ជូនពីត្រង់ណោះទៅត្រង់ណោះ ទៅត្រង់ណោះទៅត្រង់ណោះ ។

ថន ៖ ដេកតែហាលភ្លៀង ប្រកតែបាវ យប់ឡើងភ្លៀង យកបាវប្រក ។

ប៊ុនថន ៖ ប្រកម៉េចវិញ?

ថន ៖ ប្រកដេកណា ។

ជិតខាង ៖ ប្រកកុំឲ្យវាទទឹកភ្លៀងណា ។ ចុះវាមានឲ្យយើងដេក មានរោងឯណា

ថន ៖ កងចល័តទៅណោះទៅ ណោះ ។

ជិតខាង ៖ ណោះបើសិនជាភ្លៀងជោគជាំ បង្គីមួយកល់គូថ បង្គីមួយកល់ក្បាល ទុកបង្គីចោលកៀនអីចេះខ្លាចបាត់បង្គី តែបាត់បង្គីគេប្រគល់យើង បង្គីនិងដងរែក គេប្រគល់កម្មសិទ្ធិ គេហៅកម្មសិទ្ធិរបស់យើង ។

ថន ៖ ដល់កៀរទៅដល់ណោះទៅ ត្រគោកកីគេដេញទៀតណាប្រជាជន ដេញនិរតី ចាប់និរតីគេថាវះពោះប្រកស្មៅ វាខ្លាចណា វាបែកអស់ទៅបានខ្ញុំមកផ្ទះ រកផ្ទះមកផ្ទះ មិនទាន់ដល់ផ្ទះទេ ដេកនៅរហាល ដេកតាមផ្លូវ មានឆ្នាំងមានអីរែកធ្ងន់បោះចោលអស់ ។

ជិតខាង ៖ ខ្ញុំកាលណោះម៉េចដើរដល់ ។

ថន ៖ មកដល់ យើងមកដល់ជួបម៉ែឪ យើងអរទៅ អ្នកណាដល់គ្មានម៉ែមានឪក៏យំរំពងទៅ ។

ជិតខាង ៖ ម៉ែឪគេយកទៅសម្លាប់អស់ទៅ ។

ថន ៖ ពួកអ្នកថ្មី ។

ប៊ុនថន ៖ ហើយមីងការឆ្នាំណាដែរ?

ថន ៖ អាតយ អាយុប៉ុន្មានហើយ? ចូល២៤-២៥ទេដើង ឆ្នាំខាល ។

ប៊ុនថន ៖ ក្រោយទេ ។

ថន ៖ ៨២-៨៣ទេ ។

ប៊ុនថន ៖ ហើយសព្វថ្ងៃមានកូនប៉ុន្មាននាក់?

ថន ៖ កូនបួន ។

ប៊ុនថន ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ថន ៖ ប្រុសពីរ ស្រីពីរ ។ នេះស្រីតូចជាងគេ ។

ប៊ុនថន ៖ ចុះអ្នកមីងដូចថាឆ្លងកាត់សម័យខ្មែរក្រហមហ្នឹង មីងដូចថាមានកន្លែងណាដែលមីងចាំជាងគេ ចង់និយាយថាដូចថារៀបរាប់ ចង់រៀបរាប់ឲ្យបានច្បាស់លាស់ ថាកន្លែងដែលមានចងចាំអីចឹងណា?

ថន ៖ ខ្ញុំចាំណា គេជម្លៀសខ្ញុំទៅស្រែះ ចេញពីស្រែះមក គេឲ្យទៅភូមិប៉ោយក្លឿង ចេញពីប៉ោយក្លឿងទៅលើកទំនប់នៅរន្ទះបាញ់កងចល័ត ។ ដល់ពេលចេញពីរន្ទះបាញ់ទៅ ទៅនៅតាប៉ុនលើកអាទំនប់ខ្វាយខ្វាត់នោះ តាមភ្លឺស្រែលើកភ្លឺស្រែ ដល់បញ្ចូនពីភ្លឺស្រែគេឲ្យទៅនៅត្រង់ណោះឯងបានតនៅទឹកត្រពាំងថ្ម ដល់ពេលនោះយ៉ាប់ខ្លាំងគេឲ្យមកនៅចម្ការដើម-គបីដើម ចេញពីដើម-គបីដើមទៀតបានកំណត់មកនៅត្រង់នេះតាប៉ុន ។

ប៊ុនថន ៖ មីងចុងក្រោយខ្ញុំចង់សួរមីងមួយសំណួរទៀតដូចថា សព្វថ្ងៃមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មីងយល់យ៉ាងម៉េចដែរចំពោះតុលាការកាត់ទោស?

ថន ៖ ខ្ញុំមិនដែលសួរបានដឹងផង មិនដែលបាន ។

ជិតខាង ៖ យល់ថាកាត់ទោសហ្នឹងវាត្រឹមត្រូវ ឬក៏អត់ ។

ប៊ុនថន ៖ ឬមួយក៏មិនបាច់កាត់ទោសទេ គាត់ចាសៗអស់ហើយ ។

ថន ៖ ទេ! សមតែកាត់ទោស បើសិនជាការលំបាកវាច្រើនណាស់ ការឈឺចាប់វាច្រើន មិនដឹងថាអត់ទោស ទោះបីជាអត់ទោស វាអត់ទោសមិនបានទេបើសិនខ្ញុំសព្វថ្ងៃ ។

ជិតខាង ៖ និយាយឲ្យត្រង់ទៅមានកម្លាំង មានកូនចិត្ត ខ្ញុំអត់មិនបានទេ ។

ថន ៖ ម៉ែឪឈឺសឹងតែទៅមើលមិនបានផង

ប៊ុនថន ៖ ចុះមីងមានអីចង់បន្ថែមទៀតទេមីង ដែលខ្ញុំអត់បានសួរណា?

ជិតខាង ៖ មានអីចង់ត្រង់ណាទៀតក៏ប្រាប់គាត់ទៅ ។

ប៊ុនថន ៖ ថាមីងនៅចាំអីចឹងណាខ្ញុំអត់បានសួរមីងអាចបន្ថែម?

ថន ៖ ទេយើងនិយាយអស់ទៅហើយ ។

ប៊ុនថន ៖ អីចឹងខ្ញុំអរគុណមីងច្រើនហើយ ។

ថន ៖ ចាស!

«ចប់»